# NEWS RELEASE

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

## កម្ពុជា៖ ក្រុមអ្នកជំនាញ អ.ស.ប ថ្កោលទោសចំពោះការផ្តន្ទាទោសមេដឹកនាំសហជីពកម្មករ ការបង្ក្រាបជាប្រព័ន្ធទៅលើអ្នកការពារសិទ្ធិមនុស្ស

ទីក្រុងហ្សឺណែវ (២៤ សីហា ២០២១) – ក្រុមអ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប បានរិះគន់យ៉ាងខ្លាំងៗចំពោះអាជ្ញាធរកម្ពុជាជុំវិញការផ្តន្ទាទោសអ្នកការពារសិទ្ធិមនុស្សដ៏លេចធ្លោមួយរូបគឺ លោក រ៉ុង ឈុន ដែលត្រូវបានតុលាការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារកាលពីសប្តាហ៍មុន រួមជាមួយនឹងអ្នកគាំទ្រគាត់ចំនួនពីររូបទៀត ចំពោះការអត្ថាធិប្បាយដែលគាត់បានធ្វើនៅលើហ្វេសប៊ុក ដែលអះអាងអំពីការបាត់បង់ដីសហគមន៍ និងការបណ្តេញចេញដោយបង្ខំនៅតាមបន្ទាត់ព្រំដែនកម្ពុជាវៀតណាម។

សាលាដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោសលោក ឈុន សកម្មជនសហជីពកម្មករឲ្យជាប់ពន្ធនាគាររយៈពេល ២ ឆ្នាំ។ កញ្ញា ស កន្និកា និង លោក តុន និមល ត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល ២០ ខែ ពីបទចូលរួមក្នុងការធ្វើបាតុកម្មមួយកាលពីមួយឆ្នាំមុន ដោយអំពាវនាវឱ្យមានការដោះលែងគាត់ពីការឃុំខ្លួនជាបណ្តោះអាសន្ន។

លោក វិទិត ម៉ុនតារបន (Mr. Vitit Muntarbhorn) អ្នករាយការណ៍ពិសេស អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានមានប្រសាសន៍ថា "ការដាក់ពន្ធនាគារ និងការពិន័យយ៉ាងធ្ងន់ធ្ងរដល់សកម្មជនទាំងបីរូបនេះ មានលក្ខណៈមិនសមហេតុផល និងមិនសមាមាត្រឡើយ" ។ លោកបន្តទៀត "ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំងដែលតុលាការផ្តន្ទាទោសអ្នកការពារសិទ្ធិមនុស្សទាំងបីរូបនេះ ចំពោះកម្មភាពដែលត្រូវបានការពារដោយសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិជួបប្រជុំដោយសន្តិវិធី ជាសិទ្ធិដែលធានាការពារដោយច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ" ។

អ្នកស្រី ម៉ារី ឡូល័រ (Mary Lawlor) អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស បានមានប្រសាសន៍ថា " អ្នកការពារសិទ្ធិមនុស្សមិនគួរត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬផ្តន្ទាទោសចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីការពារសិទ្ធិមនុស្សអ្នកដទៃឡើយ" ។

"យើងមានកង្វល់ជាខ្លាំងដែលរដ្ឋាភិបាលកម្ពុជា ប្រើប្រាស់មាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ "បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ" ដែលប្រើពាក្យពេចន៍ស្រពិចស្រពិល ដើម្បីបង្ក្រាបមតិជំទាស់ និងបំបិទមាត់ការបញ្ចេញមតិដោយសេរី" ក្រុមអ្នកជំនាញបានមានប្រសាសន៍បន្ថែមដូច្នេះ។

ក្រុមអ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប បានសរសេរម្តងហើយម្តងទៀត មករដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំមុន ដោយលើកឡើងនូវកង្វល់អំពីការគំរាមកំហែងប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សចំនួន២៥ នាក់ ដែលត្រូវបានគេរាយការណ៍ថាបាននិងកំពុងទទួលរងការបំភិតបំភ័យ អំពើហិង្សា ឬការឃុំខ្លួន។ ក្រុមអ្នកជំនាញបានរិះគន់ដល់ការបដិសេធជាប្រព័ន្ធនូវពាក្យសុំនៅក្រៅឃុំ សូម្បីតែ ជាគោលការណ៍ ក្រោមច្បាប់កម្ពុជា ជនជាប់ចោទគួរតែមានសេរីភាព ក្នុងខណៈពេលរង់ចាំការជំនុំជម្រះ។ ការនេះរិតតែសំខាន់ថែមទៀត នៅពេលនេះ នៅពេលដែលប្រព័ន្ធពន្ធនាគារមានមនុស្សច្រើនចង្អៀតណែន ហើយមានជនជាប់ឃុំ និងអ្នកទោសរាប់រយនាក់បានធ្វើតេស្តិ៍វិជ្ជមានជំងឺកូវីដ-១៩ នេះបើតាមប្រសាសន៍របស់ក្រុមអ្នកជំនាញ។

ក្រុមអ្នកជំនាញមានកង្វល់ជាខ្លាំងផងដែរ ចំពោះព័ត៌មានដែលគួរឱ្យជឿជាក់ថាមានអ្នកការពារសិទ្ធិមនុស្សចំនួន ១៧ នាក់ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សដទៃទៀត ដែលបច្ចុប្បន្ន បាននិងកំពុងជាប់ឃុំ ត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសតាមមាត្រា ៤៩៤ និង ៤៩៥ ។

"យើងមានកង្វល់ជាខ្លាំងដែលមាត្រាទាំងពីរនេះ ត្រូវបានប្រើប្រាស់ជាប្រព័ន្ធដើម្បីកំណត់គោលដៅទៅលើអ្នកការពារសិទ្ធិមនុស្ស" ក្រុមអ្នកជំនាញបានមានប្រសាសន៍បន្តទៀតថា " យើងសូមអំពាវនាវឱ្យរដ្ឋាភិបាលបញ្ឈប់ការប្រើប្រាស់ច្បាប់ ដើម្បីកំណត់គោលដៅលើបុគ្គលទាំងឡាយដែលកំពុងធ្វើការដើម្បីលើកកម្ពស់ និងការពារសិទ្ធិអ្នកដទៃ" ។

ក្នុងសំណុំរឿងរបស់តុលាការកាលពីសប្តាហ៍មុន លោក ឈុន និងអ្នកគាំទ្រគាត់ ត្រូវបានតុលាការបង្គាប់ឱ្យបង់ប្រាក់ពិន័យចំនួន ៥០០ ដុល្លារអាមេរិកក្នុងម្នាក់ៗ និងពិន័យជាប្រាក់មួយចំនួនផ្សេងទៀត ដែលស្មើនឹងប្រមាណជា ១០ ម៉ឺនដុល្លារអាមេរិក ទៅឱ្យគណៈកម្មាធិការកិច្ចការព្រំដែនកម្ពុជា ដោយអះអាងថាបានធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់គណៈកម្មាធិការនេះ។

" យើងមានកង្វល់ជាខ្លាំងដែលមិនឃើញមានការពន្យល់ណាមួយអំពីរបៀបដែលអ្នកការពារសិទ្ធិមនុស្សទាំងបីរូបនេះ ត្រូវបានសន្មត់ថាបង្កឱ្យប៉ះពាល់ដល់គណៈកម្មាធិការនេះ" ក្រុមអ្នកជំនាញសិទ្ធិមនុស្ស បានមានប្រសាសន៍បន្ថែមទៀតថា "ហើយពិតជាគ្មានការពន្យល់ណាមួយអំពីការធ្វើខូចកេរ្តិ៍ឈ្មោះដែលឃើញថាអាចនាំធ្វើឱ្យមានការពិន័យជាប្រាក់ដ៏ច្រើនហួសហេតុបែបនេះទេ" ។

ក្រុមអ្នកជំនាញ អ.ស.ប បានរំលឹកកម្ពុជាថា កម្ពុជាបានប្តេជ្ញាចិត្ត នាសម័យប្រជុំពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ឆ្នាំ២០១៩ របស់ខ្លួន ដើម្បី "បញ្ចប់ការយាយីរំខាន និងការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្សដោយ

បំពាន" និង " បង្កើតលក្ខខណ្ឌចាំបាច់ ដើម្បីអនុញ្ញាតឱ្យបុគ្គលទាំងអស់ ទទួលបានសិទ្ធិជាមូលដ្ឋាន ជាពិសេស សេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិចូលរួមជាសមាគម និងសិទ្ធិជួបប្រជុំដោយសន្តិវិធី"។

ក្រុមអ្នកជំនាញ ដែលបានធ្វើទំនាក់ទំនងជាមួយរដ្ឋាភិបាលអំពីបញ្ហានេះ បានជំរុញឱ្យអាជ្ញាធរអនុវត្តឱ្យបានល្អ តាមការសន្យារបស់ខ្លួន៖ " យើងលើកទឹកចិត្តឱ្យអាជ្ញាធរចាត់វិធានការជាក់ស្តែងដើម្បីអនុវត្តការ ប្តេជ្ញាចិត្ត ដែលពួកគេបានធ្វើដើម្បីបញ្ចប់ការបំភិតបំភ័យ និងការយាយីរំខានដល់អ្នកការពារសិទ្ធិ មនុស្ស។

**ចប់**

**** ក្រុមអ្នកជំនាញ៖ លោក វិទិត ម៉ុនតារបន (Mr. Vitit Muntarbhorn)*** អ្នករាយការណ៍ពិសេសស្តីពីស្ថានភាព សិទ្ធិមនុស្សនៅកម្ពុជា ***អ្នកស្រី ម៉ារី ឡូល័រ (Mary Lawlor)*** អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិ មនុស្ស ***លោក បាឡាគ្រឹសណាន រ៉ាចាកូប៉ាល់ (Balakrishnan Rajagopal)*** អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមាន លំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិទទួលបានកម្រិតជីវភាពរស់នៅគ្រប់គ្រាន់ និងសិទ្ធិមិនរើសអើងនៅ ក្នុងបរិបទនេះ និង លោក ***លោក ក្លេមែនត៍ វ៉ូលេ (Clément Voule)*** អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិចូលរួមជា សមាគម និងសិទ្ធិជួបប្រជុំដោយសន្តិវិធី។

*អ្នករាយការណ៍ពិសេស គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅ មួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលដោះស្រាយស្ថានភាពសិទ្ធិមនុស្ស របស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ក្រុម អ្នកជំនាញនៃនីតិវិធីពិសេស ធ្វើការផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយ មិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ខ្លួនឡើយ។ ពួកគេធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការ ណាមួយ ហើយបម្រើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ។*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទង៖ លោក ចូហាន់ ប៊ូឆាដ (Johanne Bouchard) តាមទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៦៣០ ឬ តាមរយៈអ៊ីម៉ែល៖ jbouchard@ohchr.org)*

*សម្រាប់ការសាកសួរព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖ លោក រ៉ូណាតូ ឌឺ សូហ្សា (Renato de Souza) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨ ៩៨៥៥) ឬអ៊ីម៉ែល៖ rrosariodesouza@ohchr.org) ឬលោក ហ្សេរីមី ឡូរេង់ស៍ (Jeremy Laurence) តាមរយៈទូរស័ព្ទលេខ៖ (+ ៤១ ២២ ៩១៧ ៧៥៧៨) អ៊ីម៉ែល៖ jlaurence@ohchr.org)*

*តាមដានព័ត៌មានទាក់ទងនឹងក្រុមអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យរបស់ អ.ស.ប តាមបណ្តាញទ្វីធទ័រ*
*Twitter@UN_SPExperts*

*តើអ្នកខ្វល់អំពីពិភពលោកដែលយើងរស់ ឬទេ?*

***ដូច្នេះ ក្រោកឈរ ដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ។***

*ហើយចូលទៅកាន់គេហទំព័រ http://www.standup4humanrights.org*